មនុស្សណេក

គោលជំនឿ៖ ផ្នែកទីប្រាំ
សាឡូមក្នុំពេញ

មនុស្សលោក

យើងខ្ញុំជឿថា ព្រះជាម្ចាស់បានបង្កើតមនុស្សលោកមកឲ្យមានលក្ខណៈដូចរូបអង្គទ្រង់ ។ មនុស្សដើមដំបូងឈ្មោះអ័ដាម និងអេវ៉ា បានធ្លាក់ក្នុងអំពើបាប ដោយការមិនស្តាប់បង្គាប់ព្រះជាម្ចាស់ ហើយជាលទ្ធផល សេចក្តីស្លាប់បានចូលមកក្នុងលោកីយ៍នេះ

ហើយមនុស្ស គ្រប់រូបបានទទួលនិស្ស័យបាបពីមនុស្សដើមដំបូងនោះ ទាំងប្រព្រឹត្តបាបដោយខ្លួនឯងផង។ ដោយសារតែអំពើបាប មនុស្សគ្រប់គ្នាត្រូវស្លាប់។ មនុស្សគ្រប់រូបមានជីវិតតែមួយគត់ ហើយបន្ទាប់ពីស្លាប់ ពួកគេនឹងទទួលការជំនុំជម្រះពីព្រះជាម្ចាស់។

យើងខ្ញុំជឿថា ព្រះជាម្ចាស់បាន
បង្កើតមនុស្សលោកមកឲ្យមាន
លក្ខណៈដូចរូបអង្គទ្រង់ ។

១) លោកុប្បត្តិ ១:២៧ ទំព័រ ៦

ទ្រង់ក៏បង្កើតមនុស្សឲ្យដូចរូបអង្គទ្រង់ គឺបានបង្កើតគេឲ្យចំនឹងរូបអង្គទ្រង់នោះឯង ក៏បង្កើតគេទ្បើងជាប្រុសជាស្រី

២) **អេភេសូ ៤:២៤** ទំព័រ ១៥១៧

ព្រមទាំងប្រដាប់ខ្លួន ដោយមនុស្សថ្មីវិញ ដែលកើតមកក្នុងសេចក្ដីសុចរិត ហើយក្នុងសេចក្ដីបរិសុទ្ធរបស់ផងសេចក្ដីពិតតាមភាពព្រះ ។


សេចក្តីពិតដែលថា
ព្រះជាម្ចាស់ចានបង្កើតមនុស្សដូច
រូបព្រះអង្គ នោះមានន័យថា
មនុស្សលោកជាតំណាងព្រះអង្គ
ហើយមានលក្ខណៈដូចព្រះអង្គ
- Wayne Grudem -

លក្ខណៈរបស់
ព្រះជាម្ចាស់

លក្ខណៈចម្លង

- គ្រប់គ្រាន់ដោយខ្លួនឯង Self-sufficient
- ស្ថិតនៅដោយខ្លួនឯង Self-existent
- ស្ថិតនៅអស់កល្ប Eternal
- មិនប្រែប្រួល Unchanging
- សព្វវ័ត្តមាន Omnipresent
- សព្វានុភាព Omnipotent
- សព្វញ្ញាតញ្ញាណ Omniscient
- គ្មានដែនកំណត់ Infinite

លក្ខណៈមិនចម្លង

- ភាពស្អាត Beauty
- សេរីភាព Freedom
- សិរីរុងរឿង Glory
- សុភាព Goodness
- បរិសុទ្ធ Holiness
- ប្រចណ្ឌ Jealousy
- ចំណេះដឹង Knowledge
- ក្តីស្រឡាញ់ Love
- ក្តីមេត្តា Mercy
- សុខសាន្ត Peace
- ភាពគ្រប់លក្ខណ៍ Perfection
- ក្តីសុចរិត Righteousness
- ក្តីពិត Truthfulness
- បំណង Will
- ប្រាជ្ញា Wisdom
- ក្តីក្រោធ Wrath

គោលជំនឿ៖ ផ្នែកទីប្រាំ
សាឡូមភ្នំពេញ

http://www.shalomphnompenh.com - based on http://goo.gl/pyIWdE

មនុស្សដើមដំបូងឈ្មោះអ័ដាម និងអេវ៉ា
បានធ្លាក់ក្នុងអំពើបាប ដោយការមិនស្តាប់
បង្គាប់ ព្រះជាម្ចាស់ ហើយជាលទ្ធផល
សេចក្តីស្លាប់បានចូលមកក្នុងលោកីយ៍នេះ

៣) លោកុប្បត្តិ ២:១៦–១៧ ទំព័រ ៦

១៦ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់បង្គាប់ទៅអ័ដាមថា ឯងនឹងស៊ីផ្លែ
ឈើទាំងអស់ក្នុងសួនច្បារនេះបានតាមចិត្ត ១៧តែឯត្រង់ដើម
ដឹងខុសត្រូវ នោះមិនត្រូវឲ្យឯងស៊ីផលទ្បើយ ដ្បិតនៅថ្ងៃណា
ដែលឯងស៊ី នោះនឹងត្រូវស្លាប់ជាមិនខាន ។

៤) លោកុប្បត្តិ ៣:៦ ទំព័រ ៧

កាលស្ត្រីបានឃើញថា ផ្លែឈើនោះបរិភោគបាន ក៏ជាទីគាប់ដល់ភ្នែក ហើយជាដើមដែលល្អមគួរនឹងចង់បាន ដើម្បីឲ្យបានប្រាជ្ញា នោះនាងក៏យកផ្លែមកបរិភោគ ព្រមទាំងចែកឲ្យដល់ប្តីដែរ គាត់ក៏បរិភោគតាម

៥) វិវរណៈ ២០:១៤–១៥ ទំព័រ ១៦១៤

១៤ចំណែកសេចក្តីស្លាប់ នឹងស្ថានឃុំព្រលឹងមនុស្សស្លាប់ នោះ
ត្រូវបោះទៅក្នុងបឹងភ្លើងដែរ នេះជាសេចក្តីស្លាប់ទី២
១៥បើអ្នកណាគ្មានឈ្មោះកត់ទុកក្នុងបញ្ជីជីវិត អ្នកនោះត្រូវ
បោះទៅក្នុងបឹងភ្លើង ។

ហើយមនុស្ស គ្រប់រូបបានទទួលនិស្ស័យ
បាបពីមនុស្សដើមដំបូងនោះ ទាំងប្រព្រឹត្ត
បាបដោយខ្លួនឯងផង។

៦) រ៉ូម ៥:១២ ទំព័រ ១៤៥៦

ដូច្នេះ ដែលបាបបានចូលមកក្នុងលោកីយ ដោយសារមនុស្ស
តែម្នាក់ ហើយក៏មានសេចក្ដីស្លាប់ចូលមកដែរ ដោយសារអំពើ
បាបនោះជាយ៉ាងណា នោះសេចក្ដីស្លាប់បានឆ្លងរាលដាល
ដល់មនុស្សគ្រប់គ្នាយ៉ាងនោះដែរ ដ្បិតគ្រប់គ្នាបានធ្វើបាប
ហើយ

៧) លោកុប្បត្តិ ៥:៣ ទំព័រ ៩

ឯអ័ដាមគាត់រស់នៅបាន១៣០ឆ្នាំ នោះទើបបង្កើតបានកូនប្រុស១តាមរូបភាពគាត់ ហើយមើលទៅដូចជាគាត់ ក៏ឲ្យឈ្មោះថា សេត

៨)អេភេសូរ ២:៣ ទំព័រ ១៥១៤

យើងរាល់គ្នាទាំងអស់ក៏បានប្រព្រឹត្តក្នុងពួកនោះពីដើមដែរ ដោយសេចក្តីប៉ងប្រាថ្នារបស់សាច់ឈាមយើង ទាំងប្រព្រឹត្ត សេចក្តីដែលសាច់ឈាម នឹងគំនិតយើងចង់បានផង ហើយ តាមកំណើតយើង នោះយើងជាមនុស្សជាប់ក្នុងសេចក្តីខ្ជាល់ ដូចជាមនុស្សឯទៀតដែរ

ដោយសារតែអំពើបាប
មនុស្សគ្រប់គ្នាត្រូវស្លាប់។

៩) រ៉ូម ៦:២៣ ទំព័រ ១៤៥៨

ដ្បិតឈ្នួលរបស់អំពើបាប នោះជាសេចក្ដីស្លាប់...

មនុស្សគ្រប់រូបមានជីវិតតែមួយគត់
ហើយបន្ទាប់ពីស្លាប់ ពួកគេនឹងទទួល
ការជំនុំជម្រះពីព្រះជាម្ចាស់។

១០) ហេព្រើរ ៩:២៧ ទំព័រ ១៤៥៨

ហើយដោយព្រោះបានដំរូវត្រូវឲ្យមនុស្សទាំងអស់ស្លាប់១ដង
រួចសឹមជាប់សេចក្ដីជំនុំជំរះ

សេចក្ដីសង្គ្រោះ

គោលជំនឿ ផ្នែកទីប្រាំ
សាឡូមភ្នំពេញ

សេចក្តីសង្គ្រោះ

យើងខ្ញុំជឿថា អស់អ្នកណាដែលប្រកាសថា ព្រះយេស៊ូវជាព្រះអម្ចាស់ ហើយជឿក្នុងចិត្តថា ព្រះជាម្ចាស់បានប្រោសឲ្យទ្រង់រស់ពីការសុគតឡើងវិញ នោះអ្នកនោះនឹងបានសង្គ្រោះជាពិត។ មនុស្សទទួលបានសេចក្តីសង្គ្រោះដោយសារព្រះគុណ មិនមែនដោយសារការខំប្រឹងប្រព្រឹត្តល្អនោះទេ។

យើងខ្ញុំជឿថា អស់អ្នកណាដែលប្រកាសថា ព្រះយេស៊ូវជាព្រះអម្ចាស់ ហើយជឿក្នុងចិត្តថា ព្រះជាម្ចាស់បានប្រោសឲ្យទ្រង់រស់ពីការសុគតឡើងវិញ នោះអ្នកនោះនឹងបានសង្គ្រោះជាពិត។

១) រ៉ូម ១០:៩ ទំព័រ ១៤៦៣

បើមាត់អ្នកនឹងទទួលថ្លែងប្រាប់ពីព្រះអម្ចាស់យេស៊ូវ ហើយអ្នកជឿក្នុងចិត្តថា ព្រះបានប្រោសឲ្យទ្រង់រស់ពីស្លាប់ឡើងវិញ នោះអ្នកនឹងបានសង្គ្រោះពិត

មនុស្សទទួលបានសេចក្ដីសង្គ្រោះ
ដោយសារព្រះគុណ មិនមែនដោយសារ
ការខំប្រឹងប្រព្រឹត្តល្អនោះទេ។

២) អេភេសូរ ២:៨–៩ ទំព័រ ១៥១៤

៨ដ្បិតគឺដោយព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះដោយ
សារសេចក្ដីជំនឿ ហើយសេចក្ដីនោះក៏មិនមែនកើតពីអ្នករាល់
គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ
៩ក៏មិនមែនដោយការប្រព្រឹត្តដែរ ក្រែងអ្នកណាអួតខ្លួន



មូលដ្ឋាន គ្រឹះនៃជំនឿ

FUNDAMENTALS OF THE FAITH

ថ្នាក់រៀន
សម្រាប់
សមាជិកថ្មី

03-06-16

បន្ទាប់ពីការថ្វាយបង្គំ

ថ្ងៃអាទិត្យនៃ
សមាធិកាត
02-28-16


ព្រះវរបិតា
ជា
ជា
ជា
ព្រះ
ព្រះរាជបុត្រា
ព្រះវិញ្ញាណបរិសុទ្ធ
មិនមែន
មិនមែន
មិនមែន